ការសម្ភាសន៏របស់បងស្រី ឈន់ផល្លី

ក៖ អ្នកសំភាសន៏ បូ ឆៃដែ ខ៖ អ្នកដែលត្រូវសំភាសន៏ឈ្មោះផល្លី

ក៖ ខ្ញុំបានឈ្មោះ បូ ឆៃ ដែន ជា peer leader ធ្វើការសំភាសន៏នៅថ្ងៃនេះជាថ្ងៃទី៣១ ខែ៥ ឆ្នាំ២០១៧មុនដំបូងសុំសួរបង តើបងមានឈ្មោះអីដែរ?

ខ៖ ញមឈ្មោះផល្លី

ក៖ តើបងមានឈ្មោះហៅក្រៅទេ?

ខ៖ អត់ទេ

ក៖ ចុះនៅក្នុងអត្តសញ្ញាណប័ត្ររបស់បងឈ្មោះនឹងដែរមែន?

ខ៖ ផល្លីនឹងអែង ,ញ្ចឹងអត់មានរហ័សនាមអីទេតាំងពីក្មេងបង ,អត់ទេ ។

ក៖ ហើយតើបងមានអាយុន្មានហើយឆ្នាំនេះ?

ខ៖ញមអាយុ៣៣ឆ្នាំ ,សាមបី

ក៖ ហើយតើបងកើតក្នុងឆ្នាំទីន្ទាន?

ខ៖ ញមកើតក្នុងឆ្នាំ១៩៨៦ ,ចុះឆ្នាំកើតក្នុងឆ្នាំអី ,ឆ្នាំខាល, ខាលជិះសត្វអីគេបង,ជិះខ្លា

ញ្ចឹងបានន័យថាបងអែងកាច ។

ក៖ ហើយតើស្រុកកំនើតបងនៅណាវិញ?

ខ៖ ញមស្រុកកំនើតកើតនៅស្រុកពួក ឃុំត្រីញ៉ូ
,នៅខេត្តសៀមរាបនឹងអីបង,ចាំនៅសៀមរាបនេះអែង ។

ក៖ តើបងមានបងប្អូនប៉ុន្ទានាក់ដែរ?

ខ៖ មានប្រាំបួននាក់ស្លាប់ពីរនាក់នៅសោះប្រាំពីរនាក់ ញ្ចឹងសល់ប្រាំពីរនាក់រហូតមកដល់លូវ ចាំសល់ប៉ុនណ្ណោះអែង ॥

ក៖ ញ្ចឹងតើពួកគាត់មានឈ្មោះអីគេដែរ ?

ខ៖ ឈ្មោះនែបងទីឈ្មោះនែ ឈន់ ខ្ជៀង បងទីពីរឈ្មោះ ឈន់ ឆៃ ទីបីឈ្មោះ ឈន់ ឆៀត ទីបួនញម ឈន់ ផល្លី ទីប្រាំឈ្មោះ ឈន់ ឆៃយ៉ា ស្លាប់ហើយនឹង ហើយនឹងទីប្រាំមួយឈ្មោះ ឈន់ ឆ្ម៉ាមឡៃ ស្លាប់ដែរ ដល់ពេលទីប្រាំពីរ ឈ្មោះឈន់ សិលា ទីប្រាំបី ឈន់ ឆ្ម៉ាមឡែន ទីប្រាំបួននែ ឈន់ឈ្ម៉ៀត, ជ្រើនមែនទែនឡើងប្រាំបួននាក់ ,ចាំ ប៉ុន្តែនៅសល់តែប្រាំពីរនាក់មែនទេបង ចាំ॥

ក៖ ហើយតើបងមានចងចាំសាច់រឿងពីពួកគាត់ទេបងប្អូនបង? ចាំ, បងមានចងចាំសាច់ចាំសាច់រឿងពីពួកគាត់ទេ?

ខ៖ ពីក្មេងក្មេងនោះ ,បានតែពីនាក់ក៏បានដែរអោយតែបងចងចាំពីរគាត់, ចាំបានតើ ,បងរៀបរាប់បានទេ ,រៀបរាប់អុយ
ដូចជាចងចាំសាច់រឿងអីប្រាប់ដល់ញមមក,ញមនឹងបងញមនេះណា នឹងហើយ
រៀបរាប់ម៉េចទៅ ,ដូចជាគាត់ចូលចិត្តអីញ្ចឹងណាហូបអី ចូលចិត្តអី
បងញមគាត់ចូលចិត្តដូចថាបងញមទីពីរនឹង
គាត់ចូលចិត្តហូបសំម្ពកកូរពួកញមទាំងអស់ក៏ចូលចិត្តម្ហូបនឹងទាំងអស់ ។

ក៖ ហើយចុះគាត់អាលូវរសនៅអីណាដែរ?

ខ៖ ឥលូវគាត់រស់នៅភូមិតាឯកបានប្រពន្ធទៅគាត់ទៅរស់នៅណោះ។

ក៖ ហើយចុះតើគាត់ជាមនុស្សម៉េចដែរ?
កាលនៅពីរក្មេងឬក៏ធំឡើងគាត់ចូលចិត្តលេងកំភ្លែងអីញ្ចឹងណា?

ខ៖ គាត់អត់សូវចេះនិយាយលេងទេគាត់ធម្មតា
ដូចថាពេលយាយអីទាល់តែមានការងារបានគាត់និយាយ
បើអត់ដែរមានរឿងអីទេគាត់អត់និយាយទេ

ក៖ គាត់ជាមនុស្សរៀនពូកែទេ?

ខ៖ គាត់មធ្យមនឹងអែង ,

ក៖ ចុះមានសាច់រឿងណាដែរបងចងចាំបំផុតពីបងប្អូនបងទេ?

ខ៖
មានដូចថាមានតើបងញមនឹងបន្ទាប់ញមនឹងប្រវត្តិគាត់គាត់ដូចថាគាត់កាលដើរធ្វើអីជាមួយ
គ្នាទៅរកអីក៏ដោយ មិនថារកត្រីមិនថារកអីក៏ដោយធ្លាប់រកជាមួយគ្នាពីក្មេងក្មេង
,ញ្ចឹងកាលនៅក្មេងក្មេងបងអែងចូលចិត្តរកត្រីជាមួយពួកគាត់,
ហើយគាត់ពូកែរកគាត់ចេះរក។

ក៖ តើគាត់ប្រើវិធីអីគេដើម្បីចាប់ត្រីបាន?

ខ៖ ដូចថាជួនកាលនាំគ្នាបាចទៅ ភាគច្រើននាំគ្នាទៅបាចក្រឡុក ហើយនឹងស្ពួចត្រីស្ពួចអី
គាត់ចូលចិត្តហើយបង់សំណាញ់អីក៏ចូលចិត្តដែរ ,គាត់ចេះបង់មកពីណាបង,
ចេះពីគ្នាឯងរៀនបង់ណា ។

ក៖ ហើយបងកាលបងនៅពីក្មេងតើបងចូលចិត្តលេងអីគេជាងគេជាមួយពួកគាត់?

ខ៖
ញមនោះញមដូចថាក្រៅពីរកម្ហូបរកត្រីរកអីនឹងញមចូលចិត្តលេងបាយឡំបបាយឡជាមួយពួក
គាត់ពីក្មេងក្មេងបងប្អូនពីក្មេងៗ។

ក៖ ចុះក្រៅពីលេងបាយឡំបបាយឡហើយតើបងចូលចិត្តធ្វើអីក្រៅពីនឹងទៀតអត់ ?

ខ៖ ដូចថាម៉ែញមប្រើអោយពួកញមធ្វើអីក៏ធ្វើណោះហើយ ចុះកាលនៅតូចធ្លាប់ឈ្លោះគ្នា
ឬក៏ត្រូវគ្នាល្អទេ ដូចថាឈ្លោះគ្នាខ្លះដែរឈ្លោះហើយក៏ត្រូវគ្នាវិញ
,ហើយដ៏ពេលឈ្លោះគ្នាមានវៃគ្នាធាក់គ្នាអីទេ, ទេពេលគេវៃក៏ញមរត់ទៅ។

ក៖ តើបងនឹងពួកគាត់រស់នៅក្នុងខេត្តសៀមរាបនឹងយូរប៉ុណ្ណាដែរ?

ខ៖ គឺនៅនៅខេត្តសៀមរាបនឹងតាំងពីឆ្នាំ១៩៩៣រហូតមកដល់លូវ ,ដល់លូវ ចំា

ក៖ ហើយអាលូវនឹងពួកគាត់រស់នៅអីណាខ្លះអាលូវ?

ខ៖ នៅនឹង ពួកគាត់នៅសៀមរាបនឹងទាំងអស់ ។

ក៖ ហើយអាលូវនឹងពួកគាត់កំពុងធ្វើអីគេខ្លះ ដូចជាការងារអីចឹងណា?

ខ៖ បងទីមួយនឹងទីបីគាត់បងញមគាត់ធ្វើសំណង់
បងញមទីពីរនឹងគាត់ធ្វើការខាងអប្សារានៅរុណតាឯក ចុះអ្នកផ្សេងៗទៀត
អ្នកផ្សេងទៀតមានអ្នកខ្លះធ្វើការអ្នកខ្លះនៅរៀន ឬនពៅនៅរៀន អ៉ ។

ក៖ ញ្ចឹងឬនពៅបងអែងនៅរៀនតើគាត់អាយុប៉ុន្ថាន ?

ខ៖ គាត់អាយុដប់ប្រាំបួនឆ្នាំ អ៉ទើបតែដប់ប្រាំបួន ចំា ។

ក៖ ហើយចុះអាលូវតើឈ្មោះម្តាយរបស់បងគាត់ឈ្មោះអីដែរ ?

ខ៖ គាត់ឈ្មោះ ពិនឡាំ ចុះឱពុកបស់បងឈ្មោះអីដែរ ពុកឈ្មោះ ដែក ឈន់ ។

ក៖ ហើយតើគាត់ទាំងពីរអាលូវមានអាយុន្ថានដែរបង ?

ខ៖ ពុកញមដូចជាហុកប្រាំ ម៉ែញមដូចជាហុកគត់ ។

ក៖ តើគាត់កើតក្នុងឆ្នាំណាដែរបអមានចាំទេ ?

ខ៖ អត់ចាំទេ ចុះឆ្នាំគាត់បងមានចាំទេ ចាំតើពុកញមឆ្នាំវក ដ៏ពេលម៉ែឆ្នាំជូត ។

ក៖ ញ្ចឹងតើបងមានដឹងថាគាត់កើតនៅកន្លែងណាទេ ?

ខ៖ បើពុកកើតនៅស្រុកអង្គរធំនេះអែង បើម៉ែកើតនៅភូមិ ឃុំត្រីញ៉ូរ ចំានៅសៀមរាបទាំងអស់
។

ក៖ តើឱពុករបស់បងធ្វើអ្វីដើម្បីចិញ្ចឹមជីវិតកាលពួកគាត់នៅក្មេង ?

ខ៖ គាត់ធ្វើគ្រូបង្រៀន ,គ្រូផ្នែកអីដែរ, គ្រូផ្នែកបឋម ។

ក៖ ហើយតើគាត់ជាមនុស្សមានលក្ខណះអ្វីដែរ ?

ខ៖
គាត់នោះជាមនុស្សចូលចិត្តធ្វើការងារដូចថាគាត់មិនថាការងារអីធ្វើអីធ្វើអីគាត់ចូលចិត្តធ្វើ
,អ៉ញ្ចឹងបានន័យថាអាលូវគឺគាត់ជាមនុស្សសកម្មញ្ចឹងបានន៍យថាគាត់ជាមនុស្សអត់ចេះនៅស្ងៀ

ម គាត់ធ្វើការងាររហូតអោយតែមានប្រយោជ៍, ហើយគាត់កាចទេបង គាតកាចតើ
រៃដែរនឹងណា ញ្ចឹងបានន័យថាគាត់កាច ។

ក៖ ហើយចុះតើម្តាយបងវិញតើគាត់រកស៊ីអីដែរដើម្បីចិញ្ចឹមជីវិតកាលនឹង ?

ខ៖ ម៉ែញមគាត់រកស៊ីលក់ដូចញមដែ,រញ្ចឹងអីក៏គាត់លក់ដែរ,ចំា អីក៏លក់ដែរមានអីលក់នឹង។

ក៖ តើគាត់ជាមនុស្សយ៉ាងម៉េចដែរ ?

ខ៖ ម៉ែញមមនុស្សគាត់ជាមនុស្សស្លូតទេ ចុះគាត់និយាយច្រើនទេ គាត់ធម្មតា។

ក៖ តើបងមានចាំសាច់រឿងអ្វីខ្លះពីឪពុកម្តាយរបស់បងអែង ចា
បងអែងចងចាំសាច់រឿងអីខ្លះពីឪពុកម្តាយបងអែង?

ខ៖ ដែរចាំដូចថាគាត់នែ គាត់ខំរកស៊ីចិញ្ចឹមកូន គាត់មើលថែកូនៗ
ហើយគាត់ស្រលាញ់កូនស្មើរៗគ្នា ,ហើយគាត់ដូចជាធ្លាប់ធ្វើអីមួយអោយបងចងចាំទេ, ចំា,
ចង់និយាយថាតើគាត់ធ្វើអីមួយពួកគាត់ទាំងពីធ្លាប់ធ្វើអីមួយដែរធ្វើអីមួយតើបងចងចាំទេ,
ដូចល្ងាចឡើងហូបបាយជុំគ្នា,
នោះអែងពេលល្ងាចឡើងហូបបាយជុំគ្នាហូបរួចនាំគ្នានិយាយរឿងជុំគ្នាសើចទៅ.មានអីសប្បាយ
តើ ។

ក៖ តើឪពុកម្តាយបងអែងមានធ្លាប់ប្រាប់ប្រវត្តិពួកគាត់ដល់បងអែងទេកាលគាត់នៅក្មេង?

ខ៖ ប្រាប់តើ
គាត់ថាម៉េចកាលគាត់នៅក្មេងគាត់រស់នៅឪពុកញមញ្ចឹងគាត់រស់នៅជាមួយយាយតានឹងគាត់
ថាយាយតានឹងកាចហើយពួកគាត់ខ្លាចម៉ែឪ, នឹងម៉ែឬក៏ពុកប្រាប់បង, ពុកពុក ចំា ។

ក៖ ចុះម៉ែគាត់ធ្លាប់ប្រាប់អត់ ?

ខ៖ បើម៉ែគាត់ធ្លាប់ប្រាប់ដែរថា
នែគាត់នៅជាមួយនែពុកគាត់តាំងពីតូចនឹងពុកគាត់នឹងពុកគាត់ស្លូតទេ
គាញមគាត់គាញមនឹងគាត់អ្នកលេងភ្លេងទេ ហើយតែគាញមគាត់ប្រពន្ធច្រើន
ដល់ពេលគាត់ទៅលេងភ្លេងទៅពេលគាត់មានប្រពន្ធពេលប្រពន្ធគាត់ស្លាប់គាត់យកប្រពន្ធទៀ
តប្រពន្ធគាត់ប្រាំមួយប្រាំពិល អូ
ទៅទៅដល់ពេលធម្មតាអ្នកលេងភ្លេងពីដើមបើមេម៉ាយគេអត់យកលេងភ្លេងរោងការទេ
ញ្ចឹងទាល់តែយកប្រពន្ធ ចា ទាល់តែទាំងប្តីទាំងប្រពន្ធបានគេយក
ប្រុសក៏ដោយស្រីក៏ដោយបើអត់មានប្រពន្ធប្តីអ្នកមេម៉ាយគេអត់យកលេងទេ

ចាស់ពីដើម ។

ក៖ ចុះកាលនឹងហេតុអីបានគេអត់យកអ្នកមេម៉ាយញ្ចឹង?

ខ៖ ញ្រោះអីគេខ្លាចដូចថា ខ្មែរយើងគេរៀបការពីដើមគេប្រកាន់ អ៉គេប្រកាន់ខាងនឹង
ចាគេប្រកាន់ គេប្រកាន់ដូចថាខ្លាចកូនកំលោះកូនក្រមុំនឹងមេម៉ាយតាម ចា
ទៅដល់ពេលនេះឡើងដូចថាខ្មោចយាយស្លាប់មួយញ្ចឹងគាត់យកប្រពន្ធទៀត

តានឹងពេលដែរបានកូនមួកូពីរស្លាប់តទៅទៀត
គាត់យកទៀតយកឡើងគ្រប់ជ្រាំពិលនាក់បានគាត់ស្លាប់

ក៖ ញ្ចឹងគាត់យកយកទាំងបង្ខំចិត្តមែនបង?

ខ៖ អត់ទេទេគាត់យកគាត់ស្រលាញ់ផងបំពេញតួនាទីគាត់ផង
,ញ្ចឹងកាលនឹងប្រពៃណីរាងពិបាកដែរបង, ចា៎ ។

ក៖ ចុះបងមានដឹងទេហេតុអ្វីប្រពន្ធគាត់ស្លាប់រហូតញ្ចឹងបង ?

ខ៖ មិនដឹងដែរបើថាចាស់ពីដើមគេថាដូចក្រយ៉ៅ
ក្រយ៉ៅយើងបានអ្នកប្រពន្ធស្លាប់ក៏ដូចជាបានមកស្លាប់បានមកស្លាប់
,ទោះបីសម័យអាលូវក៏ដោយញ្ចមលឺគេថាស្រីខ្លះបានប្តីប្តីស្លាប់ដែរ, ចា៎មានក្រយ៉ៅញ្ចឹងអែង
ខ្លះគេថាមានក្រយ៉ៅ ទៅដល់ពេលកាត់ក្រូភ្លេងការភ្លេងអីពីដើមគាត់បង្រៀនសិស្សផង
នឹងគាត់ច្រៀងតាមរោងការអីនឹង ពេលណាគេយកភ្លេងអីគេនិយមយកគាត់នឹងអែង
,ញ្ចឹងមួយនឹងមានតែតាម្នាក់អែង, ញ្ចឹងចូលដល់ជីដូនជីតាម្តង ។

ក៖ តើបងនៅចងចាំឈ្មោះជីដូនជីតាទាំងសងខាងទេ ?

ខ៖ ញ្ចមចាំតើឈ្មោះ ឈ្មោះអីខ្លះ ឈ្មោះយាយខាងពុកញ្ចមឈ្មោះ ឈ្មោះយាយតែ ឯតាឈ្មោះតា ដឿ
ពេលយាយខាងម៉ែ ឈ្មោះយាយលៀច ឈ្មោះតាឈ្មោះតាជ៉ាន់ ។

ក៖ គាត់កើតក្នុងឆ្នាំអីគេបងមានចាំទេ ឆ្នាំខ្មែរ បងចាំទេ?

ខ៖ អត់ចាំទេ អត់ដែរដឹងផង

ក៖ តើបងធ្លាប់ដឹងរឿងយាយតាបស់បងអែងទេ សាច់រឿងពួកគាត់បងមានដឹងទេ?

ខ៖ អត់ដឹងទេម៉ែគាត់ក្រាន់តែប្រាប់តែប៉ុននឹងអែង
,នឹងអែងដូចជាបងអែងរៀបរាប់មិញញ្ចឹងថាតាគាត់ម៉េចយាយយ៉ាងម៉េចញ្ចឹងហា,
ចុះបងនិយាយមិញតាខាងណាគេ, នោះខាងម៉ែ, ចុះខាងពុក, ខាងពុកអត់ទេ
អត់មានសាច់រឿងទេ ។

ក៖
តើក្រុមគ្រួសារបស់បងរស់នៅខេត្តសៀមរាបនឹងប៉ុន្ថានឆ្នាំហើយយូរប៉ុនណាហើយតាំងពីឆ្នាំណា
ដែរ ?

ខ៖ គឺតាំងពីបុរាណមកយាយតាគាត់អ្នកសៀមរាបទាំងអស់គ្នា ។

ក៖ ញ្ចឹងតើបងមានសាច់ញាតិដទៃទៀតដែរនៅក្រៅប្រទេសទេ ?

ខ៖ ចា៎ មាន

ក៖ តើគាត់ឈ្មោះអីគេ ហើយត្រូវជាម៉េច ?

ខ៖ ត្រូវជាតា ប្អូនជីតាខាងពុកញម ,ញ្ចឹងមានតែជីតា,
ដូចថាគាត់នឹងតាញមនឹងបងប្អូនបង្កើត ចំ ,គាត់នៅប្រទេសណាដែរបង,
គាត់នៅប្រទេសនៅនឹងសហរដ្ឋអាមេរិច នៅរដ្ឋណាដែរបង ,រដ្ឋកាលីហ្វញ៉ា ។

ក៖ ញ្ចឹងតើស្វាមីបស់បងមានឈ្មោះអីដែរ ?

ខ៖ ស្វាមីគាត់ឈ្មោះនែ លិញ អិត ។

ក៖ តើបងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរ ?

ខ៖ ញមរៀបក្នុងឆ្នាំ២០០៧ ,តើងៃទីមានចាំទេបង, អត់ចាំទេចាំថាការខែ កណ្តឹក
ដឹងតែខែកណ្តឹកញ្ចឹងមានតែខែរងារ ខែដប់មួយ ។

ក៖ ហើយតើអាពាហ៍ពិពាហ៍របស់បងរៀបចំដោយចាស់ទុំឬក៏យ៉ាងម៉េចដែរបង ?

ខ៖ ញមបានគ្នាឯងទៅសែនធម្មតា

ក៖ តើកាលនឹងបងយកថ្លៃទឹកដោះពីគាត់ន្មានដែរបង ?

ខ៖ ចំ ប្រាំរយ

ក៖ តើបងអាចប្រាប់ញមបានទេពីដើមដំបូងថាតើបងស្គាល់គ្នា
បង្កើតក្តីស្រលាញ់រៀបការដោយរបៀបណា ?

ខ៖ ចំប្តីញមគាត់ដឹកភ្ជៀវ ទៅញមធ្វើការនៅហាង ,ហាងណា ,នៅណា, ហាងនៅជិតវត្តតណ្ណាក់,
ហាងនឹងគេលក់អីគេបង, គេលក់ដូចថាម្ហូបបាយគ្រឿងក្លែម មានអីក៏លក់ដែរ
អាហារពេលល្ងាច ,បន្ទាប់មកបងជួបគាត់ពេលរត់ធុកធុកទៅ ,បងជួបគាត់ម៉េច
,គាត់ទៅហាងទៅស្គាល់ញម, ញ្ចឹងងៃនឹងកើតអីបានគាត់ទៅហាង
,គាត់ដូចថាធម្មតាកូនប្រុសមានពួកម៉ាកមិត្តភក្តិជឹកស៊ីទៅ ទៅចូលហាង រួចក៏ស្គាល់គាត់ទៅ
,គាត់ទៅដូចជាញ្ចឹងទៅចង់ដឹងអាកន្លែងនឹងមែនទែន, ដូចជាចាប់ផ្តើមនិយាយពីគ្នាឬក៏ម៉េច
ទៅនិយាយលេងធម្មតា និយាយធម្មតាញ្ចឹងទៅ, គាត់ប្រាប់ថាស្រលាញ់ទៅ
,ដ៏ពេលប្រាប់ថាស្រលាញ់ញ្ចឹងទៅបងចាប់ផ្តើមស្រលាញ់គ្នានិយាយពេលចេញពីហាងឬក៏ចាប់ដៃ
គ្នានិយាយគ្នាពីពេលនឹងសាងក្រុមគ្រួសាររហូតមកដល់លូវ
,ញមក៏ឈប់ធ្វើការនៅហាងនឹងទៅបានចាប់ផ្តើមបានគាត់ទៅញមចាប់ផ្តើមសាងគ្រួសាររហូត
ដល់លូវ ។

ក៖ ញ្ចឹងតើបងចេះអានរឺចេះសរសេរភាសាខ្មែរបានច្បាស់ទេ ?

ខ៖ ញមចេះតើសរសេរបានអានបាន

ក៖ ចុះភាសាផ្សេងបងចេះអត់ ? អត់

ក៖ ញ្ចឹងសូមប្រាប់ពីខ្សែជីវិតរបស់បងម្តងតើបងបានរៀនថ្នាក់ទីន្មានដែរកាលនៅពីតូច?

ខ៖ ញមរៀនបានត្រឹមថ្នាក់ទីបួន ញ្ចឹងបានន័យថារៀននៅសាលាបឋមសិក្សា ចំ ។

ក៖ ញ្ចឹងតើសាលានឹងនៅណាដែរបង ?

ខ៖ សាលាមុខនាគ ញ្ជឹងនៅសៀមរាបនឹងអែងបង ចា

ក៖ ញ្ជឹងតើហើយសាលារៀនរបស់បង តើបងមានចងចាំមិត្តភក្តិដ៏ស្និតស្នាលបំផុតរបស់បងទេ ?ចាំមិត្តភក្តិស្និតស្នាលទែគាត់ឈ្មោះអីខ្លះ?

ខ៖ ភ្លេចអស់ហើយ តាំងពីតូចរហូតមកដល់អាលូវតើមានមិត្តភក្តិដែរនៅចាំទេ ចា នៅមានឈ្មោះអីគេ នឹងដូចថាធ្លាប់រៀនអង់គ្លេសជុំគ្នាទៅក៏ស្គាល់គ្នាដល់លូវ ។

ក៖ តើបងមានចាំសាច់រឿងពីគាត់ទេ អត់ទេ
ហើយចុះបងធ្លាប់ធ្វើអីខ្លះកាលបងនៅរៀនជុំគាត់ ?

ខ៖ ធ្លាប់តែរៀនជុំគ្នា ទៅរៀនជុំគ្នាជួបគ្នានិយាយលេងធម្មតា
យាយរាប់អានគ្នាធម្មការហូតដល់លូវ ។

ក៖ តើបងធ្លាប់ធ្វើការនៅវាលស្រែទេ ?

ខ៖ ធ្លាប់តើ ដូចជាធ្លាប់ធ្វើអីគេ ធ្វើស្រែ

ក៖ ចុះក្រៅពីមុខរបរធ្វើស្រែនឹង តើបងមានធ្វើការអីផ្សេងទេដើម្បីទទួលបានកំរៃ

ដូចជាធ្វើអ្វីផ្សេងអីគេខ្លះ?

ខ៖ ចេះតើធ្វើច្រើន ដូចជាលក់នំចំណី លក់បន្លែ ទិញអេតចាយក៏ធ្លាប់ទិញ ធ្វើការសំណង់ធ្វើអី ធ្វើសន្តិសុខធ្លាប់ធ្វើ អោយតែការងាររកលុយគឺញមធ្លាប់ធ្វើទាំងអស់
ញ្ជឹងបងអែងមានប្រវត្តិតស៊ូច្រើន ចា ។

ក៖ តើជីវិតរបស់បងតាំងពីក្មេងរហូតមកដល់លូវតើជីវិតរបស់ផ្លាស់ប្តូរអ្វីខ្លះ ?

ខ៖ ពីក្មេងដូចថាយើងធ្លាប់រស់នៅជាមួយឪពុកម្តាយញ្ជឹង ដូចថាយើងស៊ីចុកអីលើគាត់ញ្ជឹងហា
គាត់អ្នកគិតគូររៀបចំយើងមិនមានអីត្រូវភ័យញ្ជឹងហា ដល់ទៅពេលអាលូវយើង
គផ្គត់ផ្គង់ខ្លួនយើងញ្ជឹងវាខុសផ្លែក មានដូចថាយើងវាមិនដូចមុនពីក្មេងណា
ញ្ជឹងអាលូវយើងខុសពីក្មេងយើងដឹកនាំខ្លួនអែងត្រូវធ្វើអីខ្លួនអែង ចា
ញ្ជឹងក្រៅពីផ្លាស់ប្តូរមួយនឹងតើបងមានផ្លាស់ប្តូរអីទៀតទេ
ដូចថាអនាគតទៅមុខយើងចង់ដូចថា មានប្រាក់កាសខ្លះដើម្បីនៅ
ដូចថាយើងរកស៊ីចិញ្ចឹមកូនទៅពេលកូនធំទៅត្រូវការកំរៃច្រើន ដើម្បីអោយកូនរៀនសូត្រ
ស្លៀកពាក់អីញញចឹង តាមតំរូវការរបស់កូន គឺបងគិតគូរវែងឆ្ងាយបន្ថែមទៀត
ញ្ជឹងកូនក្មេងពួកគាត់អត់សូវចេះគិតវែងឆ្ងាយអីទេដឹងតែបានមួយដៃគិតម៉ាដៃ ចា ។

ក៖ ហើយអីតើបងមានម្ហូបណាដែរបងចូលចិត្តតាំងពីក្មេងរហូតមកដល់អាលូវទែ ?

ខ៖ ចាំម្ហូបដែរចូលចិត្តញមចូលចិត្តតែសំឡកកូរនឹងអែង សំឡកកូរ ចា

ក៖ ហើយចុះល្បែងបងចូលចិត្តលេងទេចូលចិត្តលេងល្បែងអីគេតាំងពីតីចរហូតមកដល់អាលូវ ?

ខ៖ ចាញមអត់មានចូលចិត្តលេងអីផងតាំងពីក្មេងមកចូលចិត្តលេងតែបាយឡំបបាយឡ
ចុះធំឡើងនៅតែលេងទេ ចាអត់ទេធំឡើងញមឈប់លេងហើយ ដៃណានាំពួលេងម្តង ថាលេងទេ

ចុះល្បែងប្រជាប្រិយបងមានចេះលេងទេ ចេះតើ តើបងចូលចិត្តល្បែងណាជាងគេ
ដូចថាលេងបោះឈូង បោះអង្ពុញណាញំចូលចិត្ត រហូតដល់លូចេះតែចង់លេង ចំា ។

ក៖ ញ្ជឹងតើបងចងចាំចំរៀងណាជាងគេដែរបងចូលចិត្តតាំងពីក្មេងមក ?

ខ៖ ចំាចំរៀងនោះ អារឿងចំរៀងញមមិនសូវជាចូលចិត្តដែរ
អត់បានរៀនទេគ្រាន់តែស្តាប់ក៏ហើយ។

ក៖ ចុះតើមាននរណាខ្លះនៅក្នុងគ្រួសារបស់បងចេះលេងភ្លេងទេ
ដូចជាចេះលេងឧបករណ៍ភ្លេងអីទេ ?

ខ៖ មានតើប្អូនញមចេះ ប្អូនពៅនោះ
ប្អូនពៅក៏ចេះប្អូនញមទីពីបន្ទាប់ញមដូចថាប្អូនទីប្រាំពិលទីប្រាំបីទីប្រាំបួនសុទ្ធតែចេះលេងភ្លេង
ទាំងអស់នោះអែង គាត់ចេះលេងភ្លេងអីដែរ ភ្លេងបុរាណ ។

ក៖ តើគាត់ចេះលេងឧបករណ៍អីខ្លះ ប្រើអីគេ?

ខ៖ ប្អូនស្រីចេះកូតទ្រ ដ៏ពេលប្អូនប្រុសនោះគេចេះវៃរនាតវៃអីនោះ ហើយភ្លេងបុរាណគេចេះខ្លះ។
គេធ្លាប់រាំសិល្បះ គេចេះសិល្បះទាំងបីនាក់នឹង

ក៖ ទៅរៀននៅណាវិញ ?

ខ៖ គាត់រៀននៅនែសាលាអង្គការនោះ កាលពីក្មេងពួកគេនៅជុំអង្គការទាំងបីនាក់ ។

ក៖ ហើយចុះអាលូវគាត់នៅធ្វើការ រឺក៏ធ្វើអីដែរ?

ខ៖ ធ្វើការនោះអែង

ក៖ តើផ្ទះរបស់បងមានសភាពបែបណាហើយតាំងពីក្មេងរហូតមកដល់អាលូវ ?

ខ៖ ផ្ទះតាំងពីក្មេងនៅជាមួយម៉ែនោះ ,បាទតាំងពីតូចរហូតមកដល់អាលូវ,
កាលមុនដូចថាផ្ទះខ្ពស់ផុតពីដី ដូចថាបងញមគាត់បានប្រពន្ធបានអីទៅ
ម៉ែញមគាត់លក់ផ្ទះនឹង គាត់ធ្វើផ្ទះធម្មតា អ៉ុ។

ក៖ ចុះកន្លែងនេះជាផ្ទះកាលពីមុនរឺក៏ទើបតែធ្វើ?

ខ៖ ដីនេះដីតាំងពីនែជីដូនជីតាពីមុនមកដូចថាញមទើបតែធ្វើពេលដែរញមមានគ្រួសារហើយ
កាលពីមុននៅណោះនៅជុំម៉ែ ។

ក៖ ហើយអឺនៅពេលសាងសង់ផ្ទះតើបងមានបានជួយធ្វើទេ ?

ខ៖ ចំាពេលបានសង់ផ្ទះនោះ ញមបានជួយតើ។

ក៖ តើបងជួយដោយរបៀបណាធ្វើរឺក៏ជាលុយ ?

ខ៖ ញមលុយផង ជួយផង ញមកាលពីមុនផ្ទះតូចទេអាលូវបានប៉ុនណ្ណេះ
កាលញមជួយដេរស្លឹកដេរអី ធ្វើស្លឹកផ្ទះស្លឹក ។

ក៖ ហើយអឺតើនរណាបង្រៀនបងពីរបៀបដេរស្លឹកធ្វើស្លឹកអីនឹងតើបងចេះពីណាមក?

ខ៖ ចេះខ្លួនអែងយើញចាស់ទុំគាត់ដេរទៅធ្វើតាមគាត់ទៅ អូបងឆ្លាតមែន ។

ក៖ តើបងមានជំនាញអ្វីដើម្បីបន្តដល់កូនចៅជំនាន់ក្រោយទេ?

ខ៖ ញមដូចថាអត់មានជំនាញអីទេ
បើថាកូនស៊ីសងលើចារឹកនឹងចំណង់ចំណូលបស់កូនដែរធំទៅកូនចង់ធ្វើអីអោយកូនធ្វើនឹង
ស្រេចតែគាត់ គាត់ចង់ខាងអី, ចុះបងដូចជាមានជំនាញអីដូចជាចង់អោយគាត់រៀនទេ
ដើម្បីបន្តអោយគាត់, យើងអត់ទាន់មានអីមានបន្តអោយគាត់ទេ យើងគ្មានមុខរបរអីធំដុំ
ដើម្បីបន្តអោយកូន ដ៏ពេលកូនរៀនចេះទៅចាំមើលកូន មានជំនាញអីអោយកូនធ្វើនឹង ។

ក៖ តើបងអាចប្រាប់ញមបានទេតើបងនៅពេលដែរបងលំបាកជាងគេក្នុងជីវិតបស់បង
ដែរបងលំបាកជាងគេ បងធ្លាប់មានបទពិសោធន៍លំបាកខ្លាំងទេ ?

ខ៖ ចំាញមធ្លាប់មានតើ លំបាកខ្លាំងពេលដែរកូននៅតូច ពេលដែរយើងអត់បានរកអី
ហើយប្តីដល់ពេលអត់ភ្ជៀវអត់អីទៅអត់មានលុយអីទៅ គឺលំបាករកតាអង្ករហូបមិនបាន
រកតែលុយកូនទាជឹកទឹកអំពៅម៉ាពាន់មិនមានលុយអោយកូនផង ពេលនឹងធ្លាប់ដែរ។

ក៖ លំបាកខ្លាំងញ្ចឹងតើបងឆ្លងកាត់វាដោយរបៀបណា ?

ខ៖ កាលនឹងញមដូចថាញមទៅផ្ទះម៉ែក្មេកញមទៅ
គាត់អោយលុយយើងមកធ្វើដើមរកស៊ីដោះស្រាយបានម៉ាគ្រានឹង។

ក៖ ហើយកាលនឹងបងចាប់ផ្តើមបានលុយពីគាត់មកតើបងបានធ្វើអីមុនគេ ?

ខ៖
កាលនឹងពេលគាត់អោយលុយយើងមកកាលនឹងយើងធ្វើដូចថាយើងយកលុយនឹងទៅទិញដូច
ជា បន្លែត្រីសាច់លក់តាមផ្ទះទៅពេលនឹងបានអានឹងអែងកំរៃរាល់ងៃ
ចុះកាលនឹងបងយកមកលក់តាមផ្ទះវិញ អត់លក់តាមផ្សាទេ អត់ទេ
ទៅទិញផ្សាយកទៅលក់តាមផ្ទះ ចុះកាលនឹងបានចំណូលម៉េចដែរបងលក់ដាច់អត់
ដាច់តិចតិចដូចថាយើងស៊ីសងងៃណាលក់ដាច់ងៃណាក៏លក់យ៉ាប់ទៅ
ដែរបាននៅយូរទេងៃណាលក់ឆាប់ដាច់ក៏ឆាប់បានមកផ្ទះវិញលឿនទៅ
ហើយញមលក់អស់អស់រាល់ងៃ ,ញ្ចឹងដឹងតែអស់ហ្មង, ចំា
,ហើយបងដាក់ម្ចំតូរឺក៏ដាក់កង់កាលនឹង, ដាក់កង់ ដាក់នឹងកញ្ជេទៅ
,ញ្ចឹងអានឹងបទពិសោធន៍ជូរចត់,, ។

ក៖ ញ្ចឹងអាលូវបងប្រាប់ញមបានទេពីបទពិសោធន៍ល្អល្អវិញតើបងមានទេ ?

ខ៖ បទពិសោធន៍ល្អនោះអត់ទាន់មានទេ ដូចថាយើងរាងធ្លរជាងមុន
អាចថារកបានម៉ាហូបចុក ដូចថាគេមានបុណ្យ ការអីយើងមានសមត្តភាពទៅរួច
វាអត់ដូចលើកមុនណាលើកមុនគឺអត់សោះ, ញ្ចឹងបងគិតថានេះជាបទពិសោធ៍ល្អល្អក្នុងជីវិតបង
ចំា។

ក៖
ហើយនៅពេលដែរបងអែងនៅក្មេងតើបងអែងមានដែរគិតទេថាបងអែងធំឡើងចង់ធ្វើអីគេ
?

ខ៖ ចំាកាលពីក្មេងញមគិតតើគិតថាបើសិនជាយើងអាចថាមានលទ្ធភាពយើង
ញមដូចថាចង់មានកន្លែងរកស៊ីលក់ដូរណាដែរនឹងធឹងពិតប្រាកដ តែវាអត់ទាន់មាន
,នឹងបងគិតកាលពីបងនៅក្មេង, ចំា, បងអែងចង់ធ្វើជាអ្នកលក់ដូរ ។

ក៖ ចុះបើសិនជាបងអាចផ្តេផ្តាំដល់កូនចៅជំនាន់ក្រោយតើបងចង់ផ្តេផ្តាំអីគេខ្លះ ?

ខ៖ ញមចង់ផ្តេផ្តាំដូចថាកូនជំនាន់ក្រោយញមចង់ផ្តាំដូចថា
ដូចថាអោយយើងរកស៊ីដោយគំនិតខ្លួនយើង មិនអោយធ្វើដូចញមទេ កុំអោយធ្វើខ្ជុំគេ
,ចុះគាត់រៀនចេះគាត់ធ្វើការគាត់ធ្វើខ្ជុំគេអាដែលនឹង,និយាយលេងទេបង,ចំា,
ដូចថាចង់អោយរៀនរៀនពីមុខជំនាញរបស់យើងញ្ចឹងណា ដូចជាជាងដេរ ដឹងជាងដេរ
ជំនាញអ្នកម៉ៅការសំណង់ដឹងម៉ៅការសំណង់ញ្ចឹង បើថាសំអាងការអោយដឹងសំអាងការ
បើគ្រូពេទ្យអោយដឹងគ្រូពេទ្យ នឹងគឺជា គឺជានេះបស់យើងហ្មង ចំា
យើងអត់នៅក្រោមបញ្ជាណាគេទេដឹងតែគេមករកដឹងតែថាបស់យើងលើយើងហ្មង
,ញ្ចឹងបងផ្តេផ្តាំពួកគាត់អោយរៀនជំនាញកុំអោយទៅស៊ីឈ្នួលគេ ,តើបងមានអីផ្តេផ្តាំទៀតទេ,
រឿងនឹងដូចថាយើងអត់ទាន់នឹកយើញកូនអត់ទាន់ធំយើងអត់ទាន់ដឹង
ផ្តេផ្តាំអាលូវអ្វីដែរចាំបាច់ដល់កូនចៅជំនាន់ក្រោយបងអែង
អានឹងដូចថាទៅមុខទៀតយើងមានអីផ្តេផ្តាំអីញ្ចឹងតែមិនដឹងផ្តេផ្តាំអីបើកូនយើងអត់ទាន់ធំ
ពេលដែរកូនធំយើងអាចផ្តេផ្តាំ
ដល់ពេលយើងទាល់តែយើងកូនធំមានគ្រួរសារអាចតែយើងមានពាក្យប្រាប់កូន
,ដូចជាបងអែងផ្តេផ្តាំកូនធំឡើង អោយកូនចៅទាំងអស់ ជាមនុស្សស្មោះត្រង់
ធ្វើអីអោយពិតប្រាកដ ដូចជាបងអត់ចង់ផ្តេផ្តាំញ្ចឹងទេ ចំាផ្តាំញ្ចឹងអែង
។អរគុណបងសំរាប់ការធ្វើបទសំភាសន៍ងៃនឹងញ្ចឹងញមមានតែប៉ុននឹងអរគុណច្រើន ។